ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :....០៣....អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅ

## នៃគណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធ

### រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញ អនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ មានគោលបំណងធានាតម្លាភាព អព្យាក្រឹតភាព នីត្យានុកូលភាពហិរញ្ញវត្ថុ និងភាពជឿទុកចិត្តបាន នៃការដោះស្រាយវិវាទសារពើពន្ធ។

**មាត្រា២.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធ ដែលសរសេរជាអក្សរកាត់ថា "គ.វ.ស." ស្របតាមមាត្រា២៤ នៃច្បាប់ស្តីពីគយ និងមាត្រា១២៣ នៃច្បាប់ស្តីពីសារពើពន្ធ។

**មាត្រា៣.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្ត ចំពោះវិវាទគយ រដ្ឋាករ និងពន្ធដារ ដែលកើតចេញពីការមិនពេញចិត្តរបស់អ្នកជាប់ពន្ធ ចំពោះសេចក្តីសម្រេច ឬវិធានការចុងក្រោយ របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានពន្ធដារ។

## ជំពូកទី២

## សមាសភាព និងភារកិច្ច

**មាត្រា៤.-**

**គ.វ.ស.** មានសមាសភាព ដូចតទៅ÷

| | |
|---|---|
| ១-រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២-រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ០១ រូប | អនុប្រធាន |
| ៣-តំណាងក្រុមប្រឹក្សាជាតិគណនេយ្យ ០១ រូប | សមាជិក |
| ៤-អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ | សមាជិក |
| ៥-អគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង | សមាជិក។ |

សមាសភាពជាក់ស្តែងនៃ **គ.វ.ស.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៥.-**

**គ.វ.ស.** មានភារកិច្ច ដូចតទៅ÷

- ពិនិត្យ ដោះស្រាយ និងសម្រេច លើបណ្តឹងតវ៉ារបស់អ្នកជាប់ពន្ធ ដែលមិនពេញចិត្ត ចំពោះសេចក្តីសម្រេច ឬវិធានការចុងក្រោយ របស់អគ្គនាយកដ្ឋានពន្ធដារ ពាក់ព័ន្ធវិវាទពន្ធដារ ដែលបង្កើតជាកាតព្វកិច្ចចំពោះសាមីអ្នកប្តឹងតវ៉ាផ្ទាល់

- ពិនិត្យ ដោះស្រាយ និងសម្រេច លើបណ្តឹងតវ៉ារបស់អ្នកជាប់ពន្ធ ដែលមិនពេញចិត្ត ចំពោះសេចក្តីសម្រេច ឬ វិធានការចុងក្រោយ របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ពាក់ព័ន្ធវិវាទគយនិងរដ្ឋាករ ដែលបង្កើតជាកាតព្វកិច្ចចំពោះសាមីអ្នកប្តឹងតវ៉ាផ្ទាល់
- ពិនិត្យ ដោះស្រាយ និងសម្រេច លើសេចក្តីសម្រេចឬវិធានការពាក់ព័ន្ធវិវាទសារពើពន្ធចុងក្រោយផ្សេងទៀត ដែលបង្កើតជាកាតព្វកិច្ចចំពោះសាមីអ្នកប្តឹងតវ៉ាផ្ទាល់។

## ជំពូកទី៣

## កិច្ចដំណើរការ

**មាត្រា៦.-**

សមាសភាព **គ.ទ.ស.** ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានត្រូវកោះអញ្ជើញ និងដឹកនាំការប្រជុំ **គ.ទ.ស.** តាមការប្រគល់សិទ្ធិរបស់ប្រធាន។

**មាត្រា៧.-**

**គ.ទ.ស.** មានសិទ្ធិអញ្ជើញមន្ត្រីជំនាញពាក់ព័ន្ធ នៃក្រសួង ស្ថាប័ន សវនករ តំណាងវិស័យឯកជនពាក់ព័ន្ធ ដើម្បីបំភ្លឺ ឬផ្តល់យោបល់ តាមការចាំបាច់។

អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយក នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា មានភារកិច្ចបំភ្លឺលើពាក្យបណ្តឹងតវ៉ារបស់អ្នកជាប់ពន្ធ តាមការអញ្ជើញរបស់ **គ.ទ.ស.**។

**មាត្រា៨.-**

**គ.ទ.ស.** មានលេខាធិការដ្ឋានមួយ ជាសេនាធិការ ក្នុងការបំពេញមុខងាររបស់ខ្លួន។

លេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បំពេញមុខងារជាលេខាធិការដ្ឋាន **គ.ទ.ស.** ដោយមានភារកិច្ច ដូចខាងក្រោម÷

- សម្របសម្រួលការងាររដ្ឋបាល និងធានាកិច្ចដំណើរការរបស់ **គ.ទ.ស.**
- ទទួល ចុះបញ្ជី និងគ្រប់គ្រងពាក្យបណ្តឹងតវ៉ារបស់អ្នកជាប់ពន្ធ
- ពិនិត្យនិងសិក្សាស្រាវជ្រាវ លើពាក្យបណ្តឹងតវ៉ា ឯកសារ ព័ត៌មាន និងភស្តុតាងពាក់ព័ន្ធ
- តាមការអញ្ជើញរបស់ **គ.ទ.ស.** ធ្វើការជាមួយមន្ត្រីជំនាញពាក់ព័ន្ធ នៃក្រសួង ស្ថាប័ន សវនករ តំណាងវិស័យឯកជនពាក់ព័ន្ធ និងអ្នកប្តឹងតវ៉ា ដើម្បីទទួលបានការបំភ្លឺ ឬការផ្តល់ភស្តុតាងបន្ថែម សម្រាប់ជាមូលដ្ឋាននៃការរៀបចំរបាយការណ៍ជូន **គ.ទ.ស.**
- លើកសំណើដោះស្រាយបណ្តឹងតវ៉ា ជូនប្រធាន **គ.ទ.ស.** ពិនិត្យ និងសម្រេច។

**មាត្រា៩.-**

**គ.ទ.ស.** មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីបំពេញការងាររបស់ខ្លួន។

## ជំពូកទី៤
## នីតិវិធីដោះស្រាយបណ្តឹងតវ៉ា

**មាត្រា១០.-**

អ្នកជាប់ពន្ធដែលមិនពេញចិត្តនឹងសេចក្តីសម្រេច ឬវិធានការ ដែលចេញដោយអគ្គនាយកដ្ឋានពន្ធដារ មានសិទ្ធិដាក់ពាក្យបណ្តឹង ទៅអគ្គនាយកដ្ឋានពន្ធដារ ក្នុងរយៈពេល ៣០ ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទ ដែលអ្នកជាប់ពន្ធបានទទួលលិខិតជូនដំណឹងអំពីសេចក្តីសម្រេច ឬវិធានការ របស់អគ្គនាយកដ្ឋានពន្ធដារ។

អ្នកជាប់ពន្ធដែលមិនពេញចិត្តនឹងសេចក្តីសម្រេច ឬវិធានការ ដែលចេញដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា មានសិទ្ធិដាក់ពាក្យបណ្តឹង ទៅអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក្នុងរយៈពេល ៣០ ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទ ដែលអ្នកជាប់ពន្ធបានទទួលលិខិតជូនដំណឹងអំពីសេចក្តីសម្រេច ឬវិធានការ របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

**មាត្រា១១.-**

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ឬអគ្គនាយកដ្ឋានពន្ធដារ ត្រូវពិនិត្យ ដោះស្រាយ សម្រេច ឬមានវិធានការឆ្លើយតប លើពាក្យបណ្តឹងរបស់អ្នកជាប់ពន្ធ ក្នុងរយៈពេលមិនលើសពី ៦០ ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទ នៃការទទួលពាក្យបណ្តឹង។

វិធាននិងនីតិវិធីនៃការដោះស្រាយវិវាទគយនិងរដ្ឋាករ នៅកម្រិតអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ព្រមទាំងវិធាននិងនីតិវិធីនៃការដោះស្រាយវិវាទពន្ធដារ នៅកម្រិតអគ្គនាយកដ្ឋានពន្ធដារ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១២.-**

អ្នកជាប់ពន្ធដែលមិនពេញចិត្ត ចំពោះសេចក្តីសម្រេច ឬវិធានការចុងក្រោយរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ឬអគ្គនាយកដ្ឋានពន្ធដារ មានសិទ្ធិប្តឹងតវ៉ាមក **គ.ទ.ស.** ក្នុងរយៈពេល ៣០ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទនៃការទទួលលិខិតជូនដំណឹងស្តីពីសេចក្តីសម្រេចដោះស្រាយបណ្តឹងតវ៉ា ឬវិធានការចុងក្រោយរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ឬអគ្គនាយកដ្ឋានពន្ធដារ ដោយចម្លងជូនសាមីអគ្គនាយកដ្ឋាន។

**មាត្រា១៣.-**

អ្នកជាប់ពន្ធ ត្រូវដាក់ពាក្យបណ្តឹងតវ៉ាជាលាយលក្ខណ៍អក្សរ នៅលេខាធិការដ្ឋាន **គ.ទ.ស.**។

ពាក្យបណ្តឹងតវ៉ា ត្រូវមានព័ត៌មាន កម្មវត្ថុ និងមូលហេតុនៃបណ្តឹង ជាអាទិ៍ ដូចខាងក្រោម÷

- ឈ្មោះ អាសយដ្ឋាន និងលេខអត្តសញ្ញាណកម្មសារពើពន្ធ នៃអ្នកជាប់ពន្ធដែលធ្វើការតវ៉ា
- ព័ត៌មានលម្អិតនៃសេចក្តីសម្រេច ឬវិធានការ ដែលជាកម្មវត្ថុនៃការតវ៉ា
- ដើមហេតុ ឬអំពើដែលជាកម្មវត្ថុនៃការតវ៉ា
- ហេតុផល ឬមូលដ្ឋានគតិយុត្តនៃការតវ៉ា
- កាលបរិច្ឆេទ និងហត្ថលេខារបស់អ្នកជាប់ពន្ធ ឬអ្នកតំណាងរបស់អ្នកជាប់ពន្ធ
- ឯកសារ ព័ត៌មាន លិខិតយុត្តិការ និងភ័ស្តុតាងចាំបាច់ដែលជាមូលដ្ឋាន នៃការតវ៉ា

- ឯកសារ ព័ត៌មាន លិខិតយុត្តិការ និងភស្តុតាងផ្សេងទៀត ពាក់ព័ន្ធនឹងការតវ៉ា តាមការកំណត់របស់ **គ.ទ.ស.**។

គំរូនៃពាក្យបណ្តឹងតវ៉ា ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១៤.-**

ក្នុងករណីពាក្យបណ្តឹងតវ៉ាពុំបំពេញតាមលក្ខខណ្ឌកំណត់ក្នុងមាត្រា១៣ នៃអនុក្រឹត្យនេះ លេខាធិការដ្ឋាន **គ.ទ.ស.** ត្រូវស្នើសុំឱ្យអ្នកប្តឹងតវ៉ា បំពេញចំណុចដែលខ្វះខាត។

**គ.ទ.ស.** អាចចេញសេចក្តីសម្រេចបដិសេធពាក្យបណ្តឹងតវ៉ា ក្នុងករណីលក្ខខណ្ឌនៃការដាក់ពាក្យបណ្តឹងតវ៉ាពុំត្រូវបានបំពេញគ្រប់គ្រាន់ដោយអ្នកប្តឹងតវ៉ា។

**មាត្រា១៥.-**

បន្ទាប់ពីទទួលបានពាក្យបណ្តឹងតវ៉ា លេខាធិការដ្ឋាន **គ.ទ.ស.** ពិនិត្យ ស្រាវជ្រាវ និងរៀបចំរបាយការណ៍ស្តីពីបណ្តឹងតវ៉ា ជូន **គ.ទ.ស.**។

**មាត្រា១៦.-**

ការដោះស្រាយវិវាទសារពើពន្ធ អាចឆ្លងកាត់ការសម្រុះសម្រួលជាមុន ទៅតាមកម្រិត ដូចខាងក្រោម÷

- ក្នុងកម្រិតអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ឬអគ្គនាយកដ្ឋានពន្ធដារ ការសម្រុះសម្រួលត្រូវសម្រេចដោយអគ្គនាយកនៃសាមីអគ្គនាយកដ្ឋាននីមួយៗ។
- ក្នុងកម្រិត **គ.ទ.ស.** ការសម្រុះសម្រួលត្រូវសម្រេចដោយប្រធាន **គ.ទ.ស.**។

ការសម្រុះសម្រួល ត្រូវធ្វើឡើងក្នុងរយៈពេលមិនលើសពី ៣០ ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទ នៃការទទួលពាក្យបណ្តឹង ឬក្នុងរយៈពេលសមស្រប អាស្រ័យលើទំហំនិងប្រភេទរឿងនីមួយៗ។

**មាត្រា១៧.-**

ក្នុងការដោះស្រាយវិវាទ **គ.ទ.ស.** ពិនិត្យទាំងលើអង្គហេតុ និងអង្គច្បាប់។

ក្នុងករណីចាំបាច់ ប្រធាន **គ.ទ.ស.** អាចសម្រេចឱ្យមានការស្រាវជ្រាវបន្ថែមឬអធិការកិច្ចលើពាក្យបណ្តឹងតវ៉ា ដើម្បីបញ្ជាក់ ឬប្រមូលព័ត៌មាន ឬភស្តុតាងបន្ថែមពាក់ព័ន្ធអង្គហេតុ។

**មាត្រា១៨.-**

**គ.ទ.ស.** ត្រូវពិនិត្យនិងសម្រេចដោះស្រាយបណ្តឹងតវ៉ា ក្នុងរយៈពេលមិនលើសពី ៦០ ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទ នៃការទទួលពាក្យបណ្តឹង ឬក្នុងរយៈពេលសមស្រប អាស្រ័យលើទំហំនិងប្រភេទរឿងនីមួយៗ។

**មាត្រា១៩.-**

ក្នុងករណីមិនពេញចិត្តនឹងសេចក្តីសម្រេចរបស់ **គ.ទ.ស.** អ្នកជាប់ពន្ធអាចដាក់ពាក្យបណ្តឹងតវ៉ា ទៅតុលាការមានសមត្ថកិច្ច ក្នុងរយៈពេល ៣០ ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទ នៃការទទួលលិខិតជូនដំណឹងស្តីពីសេចក្តីសម្រេចរបស់ **គ.ទ.ស.** ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

បណ្តឹងរបស់អ្នកជាប់ពន្ធ ទៅតុលាការ ពុំមានអានុភាពផ្អាកការអនុវត្តសេចក្តីសម្រេចរបស់ **គ.ទ.ស.** ឡើយ។

**មាត្រា២០.-**

**គ.វ.ស.** ត្រូវចាត់តំណាងរបស់ខ្លួន នៅក្នុងកិច្ចដំណើរការនីតិវិធីតុលាការ ក្រោមការដឹកនាំនិងសម្របសម្រួលរបស់ក្រុមប្រឹក្សានីតិកម្ម នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ជំពូកទី៥**

**អវសានប្បញ្ញត្តិ**

**មាត្រា២១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័ន ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែ មករា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ